ក្រសួងទេសចរណ៍
លេខ:...២៧៧.....កទច/ក
មកដល់ ម៉ោង..................ថ្ងៃទី.២៥..២..៩៦
ចេញទៅវិញ ម៉ោង............ថ្ងៃទី...........

# ព្រះរាជក្រម

នស/រកម/០១៩៦/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# ការបង្កើតក្រសួងទេសចរណ៍

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងទេសចរណ៍ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២.-**

ក្រសួងទេសចរណ៍មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងទេសចរណ៍ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែលអាចអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជវាំងភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ : ៦១ ច.ល.

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ មករា ឆ្នាំ ១៩៩៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**